ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ❀ ៨៨

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២០៨ សជណ.ធទឧ

## សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពអាកាសធាតុ នៅព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុ រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា : បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាកំពុងទទួលរងឥទ្ធិពលខ្យល់មូសុងនិរតី និងឥទ្ធិពលប្រព័ន្ធសម្ពាធទាប ( ITCZ ) ដែលបាន និងកំពុងអូសបន្លាយ កាត់លើភាគខាងត្បូងប្រទេសឡាវ និងលើអាងទន្លេមេគង្គ ក្នុងប្រទេសថៃ និងប្រទេសឡាវ ។ ទន្ទឹមនឹងនេះ នៅក្នុងសមុទ្រចិនខាងត្បូង និងមហាសមុទ្រប៉ាស៊ីហ្វិក ក៏មានកើតឡើងនូវព្យុះចំនួន 03 បន្តបន្ទាប់គ្នា ។

ឥទ្ធិពលរបស់បាតុភូតធម្មជាតិខាងលើនេះ នឹងធ្វើឱ្យអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា ( ចាប់ពីថ្ងៃទី 09 ដល់ថ្ងៃទី 15 ខែកក្កដា ឆ្នាំ 2015 មានស្ថានភាពដូចខាងក្រោម :

១- **តំបន់ខ្ពង់រាបខាងជើង និងខ្ពង់រាបភាគឦសាន** : រួមមានខេត្តឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង ក្រចេះ រតនគិរី មណ្ឌលគិរី មានភ្លៀងធ្លាក់ពីបង្គួរទៅច្រើន ។

២- **តំបន់ទំនាបកណ្តាល** : រួមមាន ខេត្តសៀមរាប កំពង់ធំ កំពង់ចាម ព្រៃវែង មានភ្លៀងពីមធ្យមទៅបង្គួរ ។

៣- **តំបន់មាត់សមុទ្រ** : រួមមានខេត្តកោះកុង កែប កំពត និងខេត្តព្រះសីហនុ មានភ្លៀងពីមធ្យមទៅច្រើន ។ លើផ្ទៃសមុទ្រមានខ្យល់បក់បោក និងរលកខ្លាំង ។ រលកសមុទ្រអាចមានកំពស់ពី 1,00-2,00 ម៉ែត្រ ។

យោងលើស្ថានភាពអាកាសធាតុ ដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ពិសេសចំពោះបងប្អូនប្រជានេសាទសមុទ្រ និងអ្នកធ្វើដំណើរតាមសមុទ្រ សូមបង្កើនការយកចិត្តទុកដាក់ខ្ពស់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានលើស្ថានភាពអាកាសធាតុជាប់ជាប្រចាំ ហើយនឹងធ្វើសេចក្តីជូនដំណឹងបន្ថែម ជាបន្តបន្ទាប់ក្នុងករណីចាំបាច់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០១៥

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh